# NGOជំរុញឲ្យរដ្ឋាភិបាលផ្តល់ការយកចិត្តទុកដាក់ចំពោះក្រុមអ្នកប្លែងភេទ

Posted by New Youth on 3/14/14 • Categorized as ព័ត៌មានទូទៅ



ក្រុមបុរសស្រឡាញ់បុរសអំពាវនាវឲ្យសង្គមបញ្ឈប់ការមាក់ងាយនិងរើសអើងដល់ក្រុមពួកគេ ព្រោះពួកគេក៏អាចចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រួសារនិងសង្គមដែរ។ (រូបកាលពីខែវិច្ឆិកា ឆ្នាំ ២០១៣ នៅសណ្ឋាគារអ៊ីនធឺខន់ធីណិនថល)

ឆាយ សុផល
សារព័ត៌មានយុវវ័យថ្មី

ភ្នំពេញ (១៤ មីនា ២០១៤)៖ ខាណា ដែលជាអង្គការមិនមែនរដ្ឋាភិបាល (NGO) នាំមុខគេនៅក្នុងការងារឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជានៅសប្តាហ៍នេះបានស្នើឲ្យរដ្ឋាភិបាលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្កើនការយកចិត្តទុកដាក់ដល់សិទ្ធិមនុស្សប្លែងភេទ (Transgender people) ដូចជាបុរសដែលប្លែងភេទជាស្រី។

នៅក្នុងអត្ថបទមួយរបស់ខ្លួនដែលមានចំណងជើងថា "លើកកម្ពស់សមភាពអប់រំដល់ក្រុមអ្នកប្លែងភេទ ដើម្បីសមភាពយេនឌ័រ និងការអភិវឌ្ឍជាតិកាន់តែប្រសើរ" អង្គការខាណាបានសរសេរថា រាជរដ្ឋាភិបាលកម្ពុជាអាចផ្តល់អាទិភាពនៃការអភិវឌ្ឍក្រុមប្លែងភេទ តាមរយៈការបញ្ចូលបទអន្តរាគមន៍ ពិសេសលើក្រុមងាយរងគ្រោះ ដោយរួមមានក្រុមប្លែងភេទផងដែរនៅក្នុងយុទ្ធសាស្ត្រជាតិរបស់ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច ។ល។

អត្ថបទបានបញ្ជាក់ថា ការលើកតម្កើងសមភាពអប់រំ សមភាពយេនឌ័រ និងការទទួលស្គាល់របស់សង្គមដល់ក្រុមប្លែងភេទគឺជាកាតព្វកិច្ចសំខាន់មួយរបស់ស្ថាប័ន និងមន្ត្រីពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់តំបន់ និងថ្នាក់ជាតិ។

ដោយសំអាងថា ការងារអប់រំអាចក្លាយជាយុទ្ធសាស្ត្រដ៏ចម្បងឈានទៅរកភាពជោគជ័យនៃកម្មវិធីការងារប្រយុទ្ធប្រឆាំងនិងទិសដៅលុបបំបាត់មេរោគអេដស៍ អង្គការខាណាបានសរសេរថា "កម្មវិធីអេដស៍ ក៏ដូចជាក្រសួងស្ថាប័នមួយចំនួនធំមិនទាន់បានបញ្ចូល ឬជំរុញលើកទឹកចិត្តខ្លាំងក្នុងការយកចិត្តទុកដាក់ជាពិសេសលើក្រុមងាយរងគ្រោះមួយចំនួនក្នុងវិស័យអប់រំទាំងក្នុងនិងក្រៅប្រព័ន្ធនៅឡើយទេ ជាពិលសសអ្នកប្លែភេទ (Transgender people) ដែលមានយ៉ាងតិចប្រមាណ ២.៥០០នាក់ ហើយដែលអត្រាឆ្លងមេរោគអេដស៍មានខ្ពស់រហូតដល់ ៩,៨ ភាគរយ"។

ក្នុងសារអេឡិចត្រូនិច (email) ដែលបានបញ្ជូនឲ្យសារព័ត៌មាន ព្រមទាំងស្ថាប័នរដ្ឋនិងមិនមែនរដ្ឋមួយចំនួនផង លោកស្រី ពុំ សុភានី មន្ត្រីផ្នែកគោលនយោបាយនិងយេនឌ័រនៃអង្គការខាណា បានសរសេរថា ដោយសារតែក្រុមប្លែងភេទទទួលការរើសអើងមាក់ងាយខ្លាំងពីសង្គម ដែលធ្វើឲ្យពួកគាត់បាត់បង់ឱកាសក្នុងការសិក្សា ការងារ និងសិទ្ធនានា ក្នុងការចូលរួមអភិវឌ្ឍសង្គម ព្រមទាំងងាយប្រឈមមុខខ្ពស់ទៅនឹងមេរោគអេដស៍និងកាមរោគផងនោះ "អង្គការខាណាមានបំណងសុំឲ្យរាជរដ្ឋាភិបាលផ្ដល់ការយកចិត្តទុកដាក់គាំទ្រដល់ក្រុមនេះជាពិសេសដូចស្ត្រីនិងក្មេងស្រីផងដែរ"។

កាលពីថ្ងៃទី ១ មីនា ដែល "ទិវាបញ្ឈប់ការរើសអើង" ហ៊ាន ប៊ុនវីរៈ មន្ត្រីសម្របសម្រួលគម្រោងបុរសស្រឡាញ់បុរសរស់នៅជាមួយមេរោគអេដស៍របស់បណ្ដាញអ្នករស់នៅជាមួយមេរោគអេដស៍ប្រចាំកម្ពុជាបានប្រាប់សារព័ត៌មានយុវវ័យថា "បើគ្មានការរើសអើង គ្មានការមាក់ងាយ និងមានតែក្ដីស្រឡាញ់ នោះនាំឲ្យមានការអភិវឌ្ឍនិងមានសន្តិភាព" ដោយលោកបន្តថា ការរើសអើងដល់ក្រុមគោលដៅនេះមាននៅគ្រប់ស្ទើទីកន្លែងក្នុងប្រទេស សូម្បីតែនៅឯផ្ទះរបស់ខ្លួនក៏មានដែរ ដោយពួកគេខ្លះត្រូវបានសមាជិកគ្រួសារបណ្ដេញចេញពីផ្ទះនិងរស់នៅឯកោ។

ប៊ុនវីរៈ បានបញ្ជាក់ថា បុរសប្លែងភេទជាស្រី និងក្រុមបុរសស្រឡាញ់បុរសឯទៀតៗក៏អាចចូលរួមអភិវឌ្ឍគ្រួសារ និងសង្គមជាតិបានដែរ "តែការមាក់ងាយនិងការរើសអើងបានបន្ទុចបង្អាក់ពួកគេឲ្យនៅឯកោ និងបាត់បង់ឱកាសអភិវឌ្ឍសមត្ថភាពដើម្បីបម្រើគ្រួសារនិងសង្គម"។

បើតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាលបានឲ្យដឹងថា អត្រាប្រវ៉ាឡង់នៃការឆ្លងមេរោគអេដស៍នៅក្នុងចំណោមបុរសស្រឡាញ់បុរសមាន ២,១% និងក្រុមស្រីស្រស់ (ប្រុសប្លែងខ្លួនជាស្រី) មាន ៩,៨%។ របាយការណ៍បានបញ្ជាក់ថា នេះជាអត្រាមានកម្រិតខ្ពស់ដែលតម្រូវឲ្យស្ថាប័នជំនាញពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិយកចិត្តទុកដាក់ខ្ពស់និងចូលរួមកាត់បន្ថយការមាក់ងាយ និងការរើសអើងដល់ក្រុមគោលដៅនេះ។

អង្គការខាណាបានលើកយកឧទាហរណ៍មួយមកបញ្ជាក់ថា ក្រុមបុរសប្លែងខ្លួនចាស្រី បានកំណត់ខ្លួនឯងថាជាស្ត្រី និងគិតថា ពួកគេនឹងទទួលបានការកាំទ្រនិងការអប់រំដូចស្ត្រីផ្សេងៗទៀត ប៉ុន្តែជាក់ស្តែង អ្នកទាំងនោះពុំទាន់ទទួលបានការអប់រំពីថ្នាក់ជាតិទាំងក្នុងនិងក្រៅប្រព័ន្ធឲ្យបានគ្រប់គ្រាន់នៅឡើយ ពិសេសផ្នែកសុខភាពបន្តពូជ និងជំងឺអេដស៍។

ខាណាក៏បានលើកហេតុផលដែរថា យោងតាមបរិបទ វប្បធម៌ប្រពៃណីនៅក្នុងសង្គមខ្មែរ បានចាត់ទុកអ្នកប្លែងភេទជាក្រុមមនុស្សចម្លែកមានភាគតិចនៅក្នុងសង្គម ហើយរាល់កម្មវិធី អភិវឌ្ឍន៍នានា សង្គមតែងតែភ្លេចគិតដល់ក្រុមនេះ។

ប្រទេសកម្ពុជាបានប្ដេជ្ញាចិត្តជាមួយពិភពលោកថា នៅឆ្នាំ ២០២០ ខ្លួននឹងសម្រេចបាននូវគោលនយោបាយ "៣សូន្យ" គឺ សូន្យនៃការឆ្លងមេរោគអេដស៍ថ្មី សូន្យនៃការស្លាប់ទាក់ទងនឹងជំងឺអេដស៍ និងសូន្យនៃការរើសអើង៕

Link: http://www.youthcambodia.com/general-news/8169